# ព័ត៌មាន

## សិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការលើកកម្ពស់ការយល់ដឹង និងការគាំទ្រពីសហគមន៍ ក្នុងការអភិវឌ្ឍន៍ REDD+ នៅខេត្តសៀមរាប

### ១-សេចក្តីផ្តើម

គម្រោងនេះពាក់ព័ន្ធជាមួយនឹងតំបន់សហគមន៍ព្រៃឈើដែលស្ថិតនៅខេត្តសៀមរាប ហើយនឹងធ្វើការវិភាគថាតើសហគមន៍ព្រៃឈើនេះអាចចូលរួមក្នុងគម្រោង REDD+ ដោយរបៀបណា។ ទាំងនេះគឺពាក់ព័ន្ធជាមួយនឹងការវិភាគពីគុណសម្បត្តិ និងគុណវិបត្តិនៃ REDD+ ទៅលើសហគមន៍ពាក់ព័ន្ធពីតម្រូវការក្នុងការលើកកម្ពស់ការយល់ដឹងរបស់អ្នកពាក់ព័ន្ធដែលជាក្រុមគោលដៅ តម្រូវការសម្រាប់ការពង្រឹងការរៀបចំស្ថាប័នដែលសមស្រប។ ដើម្បីសម្រេចគោលដៅនេះបានពីកិច្ចប្រជុំពិភាក្សា និងវេទិកានានាក្នុងការលើកកម្ពស់ការយល់ដឹងពីគុណប្រយោជន៍ និងតម្លៃនៃREDD+ ក្នុងតំបន់នឹងត្រូវរៀបចំសិក្ខាសាលាពិភាក្សា ដើម្បីប្រមូលព័ត៌មាន និងអនុសាសន៍ដែលមានសារសំខាន់សម្រាប់ពង្រីកការអនុវត្តគម្រោង REDD+ ក្នុងសហគមន៍ព្រៃឈើក្នុងប្រទេសកម្ពុជា។ លទ្ធផលរំពឹងទុករបស់គម្រោងរួមមាន៖

- បង្កើនការយល់ដឹងដល់អ្នកពាក់ព័ន្ធ និងការបញ្ចូល REDD+ ទៅក្នុងផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ
- កំណត់បញ្ហាប្រឈម និងឧបសគ្គនានាក្នុងការអនុវត្ត REDD+
- ជម្រុញការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងការអនុវត្តន៍ REDD+
- បង្កើន/ពង្រឹងការអនុវត្តREDD+ នៅកម្ពុជា ជាពិសេសសហគមន៍ព្រៃឈើ

ផែនការនេះបានកំណត់នូវសកម្មភាពសំខាន់ៗសម្រាប់ក្រុមការងារគម្រោងអនុវត្តជាមួយនឹងមន្ត្រីជំនាញ REDD+ ដើម្បីសម្រេចគោលដៅក្នុងការលើកកម្ពស់ការយល់ដឹងដល់អ្នកពាក់ព័ន្ធគោលដៅ។ ជាពិសេសផែនការនេះនឹងផ្តល់នូវគោលការណ៍ណែនាំដល់ក្រុមការងារ និងមន្ត្រីជំនាញ REDD+ ដោយផ្តោតលើឯកសារសម្ភារដែលត្រូវរៀបចំ និងវិធីសាស្ត្រជម្រុញ ឬផ្តល់ព័ត៌មានក្នុងការលើកកម្ពស់ការយល់ដឹងដល់អ្នកពាក់ព័ន្ធគោលដៅ និងសម្របសម្រួលជាមួយលេខាធិការដ្ឋាន REDD+ កម្ពុជា ពីរបៀបដែលក្រុមការងារដំណើរការសិក្ខាសាលាផ្សព្វផ្សាយការលើកកម្ពស់ការយល់ដឹងនេះ។

### ២-គោលបំណង

ផែនការសកម្មផ្សព្វផ្សាយនេះមានគោលបំណង ដើម្បីតម្រង់ទិសសកម្មភាពដែលនឹងអនុវត្តដោយក្រុមការងារ របស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ (IRD) ក្នុងការបង្កើនចំណេះដឹងទៅដល់សហគមន៍គោលដៅ ដែលពាក់ព័ន្ធនឹងREDD+ ផែនការនេះមានគោលបំណង៖

របស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ (IRD) ក្នុងការបង្កើនចំណេះដឹងទៅដល់សហគមន៍គោលដៅដែលពាក់ព័ន្ធនឹងREDD+ ផែនការនេះមានគោលបំណង៖

១. រៀបចំសកម្មភាពផ្សព្វផ្សាយព័ត៌មានដើម្បីសម្រេចនូវលទ្ធផលត្រឡប់មកវិញ។ សកម្មភាពនេះរួមបញ្ចូលក្នុងការធ្វើផែនការផ្សព្វផ្សាយព័ត៌មាននៅទីវាល

២. រៀបចំ (ជ្រើសរើស និងប្រមូលចងក្រង) សម្ភារព័ត៌មានពាក់ព័ន្ធដែលត្រូវប្រើប្រាស់ក្នុងការងារផ្សព្វផ្សាយ និងផលិតឯកសារបន្ថែមទៀតដែលទទួលស្គាល់ដោយលេខាធិការដ្ឋានREDD+ កម្ពុជា

៣. កំណត់សកម្មភាពលើកកម្ពស់ការយល់ដឹងដែលត្រូវផ្សព្វផ្សាយព័ត៌មានទៅកាន់អ្នកទទួលផលប្រយោជន៍ ដែលជាក្រុមគោលដៅរួមមាន ការធ្វើបទបង្ហាញដោយអ្នកជំនាញ មានបទពិសោធន៍ ហើយមានចំណេះដឹងពីREDD+ និងការបង្ហាញវីដេអូរ និងឯកសារពាក់ព័ន្ធនឹងREDD+ ។

## ៣-លទ្ធផលរំពឹងទុក

ការលើកកម្ពស់ចំណេះដឹង/សកម្មភាពផ្សព្វផ្សាយ គឺរំពឹងថានឹងបង្កើនចំណេះដឹងទៅដល់អ្នកទទួលផលប្រយោជន៍ដែលជាក្រុមគោលដៅពាក់ព័ន្ធនឹង REDD+។ ដើម្បីកំណត់នូវកំណើននៃការយល់ដឹងពីREDD+ កម្រិតនៃការយល់ដឹងពី REDD+ នឹងត្រូវធ្វើការវាស់ស្ទង់ម្តងទៀត ដោយប្រើប្រាស់ឧបករណ៍ចំណេះដឹង អាកប្បកិរិយា ការអនុវត្ត (KAP) ដែលជាឧបករណ៍ប្រើប្រាស់នៅក្នុងការវាស់ស្ទង់ទិន្នន័យគោល។ ការសាកល្បងតាមវិធានស្ថិតិសមស្របនឹងត្រូវប្រើប្រាស់ដើម្បីវាស់វែងពីកម្រិតនៃការយល់ដឹងរបស់សហគមន៍ ដើម្បីប្រៀបធៀបជាមួយនឹងទិន្នន័យគោល។ គេរំពឹងថា ការបង្កើនការយល់ដឹងរបស់សហគមន៍ទៅលើ REDD+ នឹងលើកទឹកចិត្តដល់សហគមន៍ និងបញ្ចូល REDD+ ទៅក្នុងផែនការគ្រប់គ្រងសហគមន៍ព្រៃឈើរបស់ពួកគាត់។ ការលើកទឹកចិត្តសហគមន៍អំពីREDD+ គឺនៅមានការស្រពិចស្រពិលពីគំនិតរបស់ពួកគាត់ក្នុងការដាក់បញ្ចូល REDD+ ទៅក្នុងផែនការគ្រប់គ្រងសហគមន៍ព្រៃឈើនេះ។

កំឡុងពេលប្រជុំក្នុងសហគមន៍ កិច្ចពិភាក្សាមួយត្រូវបានធ្វើឡើងដើម្បីកំណត់ពីសកម្មភាពសហគមន៍ណាមួយដែលអាចបញ្ចូលសម្រាប់ជួយកាត់បន្ថយការបញ្ចេញឧស្ម័ន ឬបង្កើនការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីព្រៃឈើ ហើយថាតើសកម្មភាពនេះអាចមានតម្លៃដែលអាចពិចារណាក្នុងការពិភាក្សាពីការបែងចែកផលប្រយោជន៍យ៉ាងណានោះទេ។

## ៤-វិធីសាស្ត្រ

### ៤.១-ក្រុមគោលដៅ

សកម្មភាពផ្សព្វផ្សាយព័ត៌មាននឹងផ្តោតគោលដៅទៅលើសមាជិកសហគមន៍ព្រៃឈើ និងក្រុមប្រឹក្សាឃុំ ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការនៅក្នុងតំបន់នេះ។ ការបង្កើនការយល់ដឹងនឹងធ្វើឡើងនៅរដ្ឋបាលស្រុក និងខេត្ត។ ការធ្វើដូចនេះគឺដើម្បីគាំទ្រទៅដល់ REDD+ នៅកម្រិតថ្នាក់ភូមិ។ អង្គការក្រៅរដ្ឋាភិបាល ជាពិសេសអ្នកដែលពាក់ព័ន្ធនឹងREDD+ នឹងត្រូវអញ្ជើញចូលរួមប្រជុំ ដោយក្នុងមូលហេតុពីរយ៉ាងគឺ ១) ដើម្បីបង្កើនចំណេះដឹងរបស់ពួកគាត់តាមរយៈមេរៀន ២) ដើម្បីចែករំលែកបទពិសោធន៍របស់ពួកគេជាមួយនឹងសហគមន៍។ ការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន (ថ្នាក់ខេត្ត ស្រុក និងឃុំ) ក្នុងការបង្កើនចំណេះដឹងនេះគឺដើម្បីបង្កើតឲ្យមានការគាំទ្រទៅដល់REDD+ និងបង្កើនចំណេះដឹងរបស់ពួកគាត់ក្នុងពេលតែមួយនេះ ក្នុងការចូលរួមសកម្មភាពរបស់មនុស្សជាមួយនឹងឧស្ម័នផ្ទះកញ្ចក់ (ឧ. ការប្រើប្រាស់ដីអាស៊ីតមិនបានត្រឹមត្រូវ ការផ្លាស់ប្តូរការប្រើប្រាស់ដី ការដុត ជាដើម)។ វគ្គប្រជុំនឹងត្រូវធ្វើឡើងដោយបែកចែកជាក្រុមដូចខាងក្រោម៖

១) **ប្រជុំកម្រិតថ្នាក់ភូមិ៖**ក្នុងវគ្គនេះ សិក្ខាកាមគោលដៅគឺជាសមាជិកសហគមន៍ព្រៃឈើនៅក្នុងភូមិ។ មេភូមិ អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការនៅក្នុងតំបន់និងអ្នកតំណាងក្រុមប្រឹក្សាឃុំនិងខណ្ឌរដ្ឋបាលព្រៃឈើនឹងត្រូវអញ្ជើញឲ្យចូលរួម។ វគ្គនេះនឹងត្រូវធ្វើឡើងក្នុង ៥ភូមិដោយឡែកៗពីគ្នា។

២) **ប្រជុំកម្រិតថ្នាក់ស្រុក និងខេត្ត ៖** មន្ត្រីរដ្ឋបាលស្រុក និងខេត្ត និងរដ្ឋបាលព្រៃឈើថ្នាក់ក្រោមជាតិដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តREDD+ ។

### ៤.២-ចំណុចសំខាន់នៃការរៀបចំឯកសារផ្សព្វផ្សាយ និងសម្ភារត្រូវប្រើប្រាស់

ការផ្សព្វផ្សាយ/សកម្មភាពបង្កើនការយល់ដឹងពី REDD+ គឺផ្តោតសំខាន់លើការផ្តល់ព័ត៌មានដល់សិក្ខាកាមពីព័ត៌មានទូទៅស្តីពីការកើនឡើងកម្តៅផែនដី ផលប៉ះពាល់ឧស្ម័នផ្ទះកញ្ចក់លើការកើនឡើងសីតុណ្ហ

ភាពលើផែនដី កត្តាប៉ះពាល់ទៅលើការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាស យន្តការទីផ្សារកាបូនក្នុងការដោះស្រាយបញ្ហាការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងREDD+ នៅកម្ពុជា។

វគ្គទាំងអស់មាន៣វគ្គ៖ (១)ភូមិ (២) ស្រុក និង (៣) ខេត្ត ។ ក្រុមគោលដៅនៃវគ្គនេះមានដូចជា៖

1. ភូមិ៖ (១)គណកម្មការសហគមន៍ព្រៃឈើ (២) អង្គការក្រៅរដ្ឋាភិបាលក្នុងតំបន់ (៣)អ្នកតំណាងឃុំ និង (៤)សង្កាត់រដ្ឋបាលព្រៃឈើ
2. ស្រុក៖ (១) អភិបាលស្រុក (២) មន្ត្រីសាលាស្រុកសំខាន់ៗដែលពាក់ព័ន្ធនឹងកសិកម្ម និងបរិស្ថាន (៣) តំណាងក្រុមប្រឹក្សាឃុំ (៤)អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការនៅថ្នាក់ស្រុក និងរដ្ឋបាលព្រៃឈើថ្នាក់ស្រុក
3. ខេត្ត៖ (១)អភិបាលខេត្ត និងមន្ត្រីសាលាខេត្តសំខាន់ៗ (២) ខណ្ឌរដ្ឋបាលព្រៃឈើ និង (៣) អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការជាមួយថ្នាក់ស្រុក។

ឯកសារសម្រាប់ប្រើប្រាស់នៅក្នុងសិក្ខាសាលារួមមាន៖ បទបង្ហាញ វីដេអូ និងអង្គពិភាក្សារួម ។

## ៥-ពេលវេលា និងទីកន្លែង

នៅថ្ងៃទី ២៧-២៨ ខែកុម្ភៈ ឆ្នាំ២០១៤ នៅសណ្ឋាគារ**មនោរាជ្យអង្គរ** ខេត្តសៀមរាប។

## ៦-អ្នករៀបចំសិក្ខាសាលា

សិក្ខាសាលាផ្សព្វផ្សាយនេះរៀបចំ ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ នៃរដ្ឋបាលព្រៃឈើ ក្រោមកិច្ចសហការនិងគាំទ្រថវិកាដោយលេខាធិការដ្ឋានREDD+កម្ពុជា ដែលរួមមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| 1. បណ្ឌិត សុខហេង | ប្រធានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ |
| 2. Dr. Edward Maningo | ទីប្រឹក្សាគម្រោង |
| 3. លោក ឡុង រត្តនៈកុមារ | អនុប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ |
| 4. លោកស្រី លឹម សុភាព | ប្រធានការិយាល័យរដ្ឋបាល និងផែនការនៃវិទ្យាស្ថាន |
| 5. លោក កេត ណាង | អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ នៃវិទ្យាស្ថាន |
| 6. កញ្ញា ហៀង សុខនី | មន្ត្រីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ |
| 7. លោក យឹម ហេង | មន្ត្រីនាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ |
| 8. លោក ប្រាក់ ម៉ារីណា | នាយរងខណ្ឌរដ្ឋបាលព្រៃឈើសៀមរាប |
| 9. លោក គង់ បូរ៉ាវុធ | នាយរងសង្កាត់រដ្ឋបាលព្រៃឈើខ្វាវ |
| 10. លោក លឹម សុជី | មន្ត្រីសង្កាត់រដ្ឋបាលព្រៃឈើពួក |
| 11. លោកស្រី សរ ចន្ទី | មន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើសៀមរាប |

## ៧-សិក្ខាកាមចូលរួម

សិក្ខាសាលាផ្សព្វផ្សាយនេះនឹងមានសិក្ខាកាមចូលរួមចំនួន៩៥នាក់ក្នុងនោះមកពីរដ្ឋបាលព្រៃឈើ អាជ្ញាធរស្រុក ឃុំ បណ្តាសហគមន៍ព្រៃឈើ និងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ។

មន្ត្រីជំនាញ REDD+ នឹងរៀបចំសម្ភារពាក់ព័ន្ធទៅនឹងប្រធានបទខាងលើ ឬអាចបន្ថែមប្រធានបទផ្សេងទៀតដែលអាចបង្កើនចំណេះដឹងទៅដល់ក្រុមគោលដៅ ក្នុងគោលបំណងលើកទឹកចិត្តពួកគាត់ដើម្បីដាក់បញ្ចូលREDD+ ទៅក្នុងផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ។

មេរៀនទាំងអស់នឹងត្រូវបង្រៀនដោយប្រើប្រាស់ LCD។ វីដេអូដែលត្រូវបង្ហាញគឺទាក់ទងទៅនឹងREDD+ ដើម្បីទាក់ទាញការចាប់អារម្មណ៍ពីអ្នកស្តាប់។ វីដេអូដែលត្រូវបង្ហាញនៅកំឡុងពេលផ្សព្វផ្សាយគឺជាវីដេអូដែលអាចទាញយកមកពីគេហទំព័ររបស់លេខាធិការដ្ឋានក្រុមការងារ REDD+ (www.cambodia-redd.org) បន្ទាប់ពីវីដេអូទាំងនេះបានទទួលការអនុញ្ញាតពីលេខាធិការដ្ឋានREDD+ រួចហើយ ដើម្បីប្រើប្រាស់សម្រាប់ការផ្សព្វផ្សាយព័ត៌មាន ។

## ៤.៣ ការបង្កើត និងសិទ្ធិក្នុងការប្រើប្រាស់ឯកសារព័ត៌មាន

មន្ត្រីជំនាញ REDD+ នឹងទទួលខុសត្រូវក្នុងការបង្កើតសម្ភារព័ត៌មានសម្រាប់ប្រើប្រាស់នៅពេលបង្រៀន។ ឯកសារព័ត៌មាន ទាំងនេះនឹងបង្កើតឡើងដោយប្រើប្រាស់សម្ភារព័ត៌មានដែលបិតបង្ហាញនៅលេខាធិការដ្ឋានREDD+កម្ពុជា ឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ព័ត៌មានទាំងនេះនឹងត្រូវប្រើប្រាស់នៅក្នុងមេរៀនដែលបកប្រែជាភាសាខ្មែរ។ មេរៀនដែលត្រូវប្រើប្រាស់ដោយមន្ត្រីជំនាញ REDD+គឺត្រូវបានទទួលស្គាល់ដោយការិយាល័យ IRD និងលេខាធិការដ្ឋានក្រុមការងារ REDD+ មុនពេលប្រើប្រាស់ក្នុងការផ្សព្វផ្សាយព័ត៌មាន។

មន្ត្រី IRD ក៏នឹងអាចផលិតសម្ភារព័ត៌មាន ដែលទាញយកមកពីគេហទំព័ររបស់លេខាធិការដ្ឋាន REDD+កម្ពុជា ដើម្បីផ្សព្វផ្សាយដល់សហគមន៍។ ទាំងនេះនឹងបំពេញបន្ថែមលើមេរៀនដែលធ្វើឡើងដោយអ្នកជំនាញREDD+។ សម្ភារព័ត៌មានសម្រាប់បោះពុម្ព និងចែកចាយគឺមានលក្ខណៈជាបដាផ្សព្វផ្សាយ និងខិតប័ណ្ណ។

## ៤.៤ វិធីសាស្ត្រផ្សព្វផ្សាយ

ក្នុងចំណោមវិធីសាស្ត្រនៃការបញ្ជូនព័ត៌មាន គម្រោងនឹងបង្កើតនូវលំដាប់ថ្នាក់ព័ត៌មានប្រជុំជាមួយសហគមន៍ព្រៃឈើទាំង ៥។ គោលបំណងនេះគឺដើម្បីចែករំលែកសមាជិកសហគមន៍ព្រៃឈើនូវព័ត៌មានស្តីពី REDD+។ ដើម្បីសម្រេចគោលបំណងនៃការបញ្ជូនសារនិងបង្កើនការយល់ដឹង គឺត្រូវប្រើប្រាស់ការរួមផ្សំនូវវិធីសាស្ត្រផ្សេងៗគ្នា ដែលរួមមាន មេរៀន ការពិភាក្សា ការចែករំលែកបទពិសោធន៍ ការបង្ហាញវីដេអូ និងការចែកខិតប័ណ្ណ។

## ៥. ដំណាក់កាលសំខាន់ៗ

ការផ្សព្វផ្សាយ/សកម្មភាពលើកកម្ពស់ការយល់ដឹង នឹងធ្វើឡើងនៅក្នុងខែ មីនា ឆ្នាំ២០១៤ ដូចខាងក្រោម:

| សកម្មភាព | លទ្ធផលរំពឹងទុក/លទ្ធផល | ពេលវេលា |
|---|---|---|
| 2.0 គោលបំណងទី ១៖ ដើម្បីលើកកម្ពស់ការយល់ដឹងពី REDD ដល់អ្នកពាក់ព័ន្ធគោលដៅ | | |
| 2.3 ការរៀបចំឯកសារស្តីពី REDD+ | ឯកសារព័ត៌មានបានបោះពុម្ព | កុម្ភៈ 2014 |

| សកម្មភាព | លទ្ធផលរំពឹងទុក/លទ្ធផល | ពេលវេលា |
|---|---|---|
| 2.4 ការចែកចាយឯកសារព័ត៌មានស្តីពី REDD+ | ឯកសារដែលចាយចាយដល់គណៈកម្មាការសហគមន៍ព្រៃឈើ ឃុំ ស្រុក និងមន្ត្រីថ្នាក់ក្រោមជាតិ | កុម្ភៈ 2014 |
| 2.5 បើកកិច្ចប្រជុំផ្សព្វផ្សាយផ្តល់ព័ត៌មានដើម្បីលើកកម្ពស់ការយល់ដឹងពី REDD+ | | |
| ▫ 2.5.1 កិច្ចប្រជុំផ្សព្វផ្សាយថ្នាក់ភូមិ (ជាមួយគណៈកម្មាការសហគមន៍ព្រៃឈើ មេភូមិ និងអ្នកតំណាងឃុំ) | កិច្ចប្រជុំផ្សព្វផ្សាយត្រូវបានធ្វើឡើង ការបង្កើនកម្រិតចំណេះដឹងពីREDD+ នៅកម្រិតថ្នាក់សហគមន៍ព្រៃឈើ និងឃុំ | កុម្ភៈ-មីនា 2014 |
| ▫ 2.5.2កិច្ចប្រជុំផ្សព្វផ្សាយជាមួយអភិបាលស្រុក និងសមាជិកក្រុមប្រឹក្សាឃុំ (អាចមានការចូលរួមពីអង្គការក្រៅរដ្ឋាភិបាល) | កិច្ចប្រជុំផ្សព្វផ្សាយត្រូវបានធ្វើឡើង ការបង្កើនកម្រិតចំណេះដឹងពីREDD+ នៅកម្រិតថ្នាក់ស្រុក | មីនា 2014 |
| ▫ 2.5.3 កិច្ចប្រជុំផ្សព្វផ្សាយជាមួយអភិបាលខេត្ត(អាចមានការចូលរួមពីអង្គការក្រៅរដ្ឋាភិបាល) | កិច្ចប្រជុំផ្សព្វផ្សាយត្រូវបានធ្វើឡើង ការបង្កើនកម្រិតចំណេះដឹងពីREDD+ នៅកម្រិតថ្នាក់ខេត្ត | មីនា 2014 |
| 2.6 ការប៉ាន់ស្មានកម្រិតយល់ដឹងនៃអ្នកទទួលផលប្រយោជន៍គោលដៅ | ការប៉ាន់ស្មានត្រូវធ្វើឡើង | មីនា 2014 |
| 2.7 ដំណើរការលទ្ធផលវាយតម្លៃ | របាយការណ៍ប៉ាន់ស្មានត្រូវបានបញ្ជូន | មីនា 2014 |

## ៦-ការផ្សាភ្ជាប់ការផ្សព្វផ្សាយទៅនឹងសកម្មភាពផ្សេងៗទៀត

បន្ទាប់ពីសកម្មភាពផ្សព្វផ្សាយ ក្រុមការងារនឹងដំណើរការកិច្ចពិភាក្សាស្តីពីលទ្ធភាពក្នុងការដាក់បញ្ចូល REDD+ ទៅក្នុងផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ។ មានសកម្មភាពថ្មីៗពីរក្នុងវគ្គពិសេសនៃសិក្ខាសាលាពិភាក្សាៈ (១)ការវាយតម្លៃកម្រិតនៃការយល់ដឹងរបស់សមាជិកសហគមន៍ព្រៃឈើស្តីពីREDD+ (២) ក្រុមពិភាក្សាពីវិធីដែល REDD+ អាចបញ្ចូលទៅក្នុងផែនការគ្រប់គ្រងសហគមន៍ព្រៃឈើរបស់ពួកគាត់ (៣) កិច្ចពិភាក្សាជាមួយអង្គការក្រៅរដ្ឋាភិបាល និងអ្នកដើរតួសំខាន់ក្នុង REDD+ ។ ការវាយតម្លៃពីកម្រិតនៃការយល់ដឹងនឹងប្រើប្រាស់នូវការសិក្សាពីគ្រួសារ (HH) ដោយប្រើប្រាស់បញ្ជីសំណួរ (KAP) ដែលបានប្រើប្រាស់នៅក្នុងការសិក្សាពីទិន្នន័យគោល។ សម្រាប់ក្រុមពិភាក្សា (FGD) ឧបករណ៍មួយដែលជាបញ្ជីសំណួរនឹងត្រូវប្រើប្រាស់ដើម្បីបញ្ជាក់ពីបញ្ហារបស់សមាជិកសហគមន៍ទៅលើសក្តានុពលក្នុងការពិចារណាពី REDD+ នៅក្នុងការអភិវឌ្ឍផែនការគ្រប់គ្រងសហគមន៍របស់ពួកគាត់។

បន្ទាប់ពីកិច្ចពិភាក្សា ក្រុមការងារធ្វើការប្រមូល រៀបចំកែសម្រួលឯកសារស្តីពីការលើកកម្ពស់ការយល់ដឹង REDD+ សម្រាប់សកម្មភាព និងការចូលរួមនាពេលអនាគត។

កិច្ចពិភាក្សាជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល រដ្ឋបាលព្រៃឈើ (ថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ) នឹងបង្ហាញពីលទ្ធផលនៃកិច្ចពិភាក្សាដែលបានធ្វើឡើង។

អ្នកតំណាងនៃលេខាធិការដ្ឋាន UN-REDD នឹងត្រូវបានអញ្ជើញដើម្បីបង្ហាញពីឧបសគ្គ និងបញ្ហាផ្សេងៗ ទៅតាមកិច្ចពិភាក្សាដែលបានធ្វើឡើងជាមួយសហគមន៍។ គោលបំណងនៃកិច្ចពិភាក្សានេះគឺដើម្បីទទួលបាននូវការដាក់បញ្ចូលសកម្មភាពចុងក្រោយដើម្បីរៀបចំនូវឯកសារបទពិសោធន៍ការងារកន្លងមក។

# ឧបសម្ព័ន្ធ ១៖ ទម្រង់នៃការវាយតម្លៃការយល់ដឹងផ្ទាល់ខ្លួន

## ព័ត៌មានពីអ្នកចូលរួមឆ្លើយ

ឈ្មោះ: ______________________ អាយុ (ឆ្នាំ) ____________

ការិយាល័យ: ______________________

តួនាទី: ______________________

អាសយដ្ឋាន: ______________________

1. តើអ្នកប៉ាន់ស្មានពីចំណេះដឹងរបស់អ្នកនៅក្នុងអតីតកាលទៅតាមចំណាងជើងខាងក្រោម ដោយវិធីណា?

| a. ការប្រែប្រួលអាកាសធាតុ | b. REDD+ |
|---|---|
| | |

2. តើអ្នកប៉ាន់ស្មានពីចំណេះដឹងរបស់អ្នកបន្ទាប់ពីបញ្ចប់មេរៀនទៅចំណាងជើងខាងក្រោម ដោយវិធីណា?

| a. ការប្រែប្រួលអាកាសធាតុ | b. REDD+ |
|---|---|
| | |

3. តើផ្នែកណាមួយនៃមេរៀនដែលអ្នកចាប់អារម្មណ៍ ឬធ្វើឲ្យអ្នកកើនឡើងចំណេះដឹង/ការយល់ដឹងពីការប្រែប្រួលអាកាសធាតុ?

4. តើមានអ្វីថ្មី ដែលអ្នកទទួលបានពីមេរៀន? ប្រសិនបើមាន តើអ្វីខ្លះ?

5. ក្នុងករណីដែលមានអ្វីថ្មី តើវាជួយក្នុងការងារ/ភារកិច្ច/ការទទួលខុសត្រូវនៅក្នុងជីវិតរបស់អ្នកឬទេ? ដោយរបៀបណា?

6. តាមយោបល់របស់អ្នក តើមានវិធីសាស្រ្តអ្វីក្នុងការផ្សព្វផ្សាយព័ត៌មានឲ្យកាន់តែមានប្រសិទ្ធភាព?

7.តើអ្នកគិតថា REDD+ នឹងផ្តល់ឱកាសដល់សហគមន៍ព្រៃឈើដែរឬទេ? ដោយរបៀបណា?

8. តើអ្នកមានស្រែចម្ការឬទេ? [ ]មាន [ ] គ្មាន (ប្រសិនបើគ្មាន សូមឈប់ឆ្លើយបន្ត)

ប្រសិនបើមានស្រែចម្ការ តើអ្នកមានដុតកំទេចកំទីដែរឬទេ? [ ]មាន [ ] គ្មាន (ប្រសិនបើគ្មាន សូមឈប់ឆ្លើយបន្ត)

ប្រសិនបើដុត តើអ្នកគិតថាអ្នកនៅតែបន្តអនុវត្តសកម្មភាពចាស់ដូចនេះទៀត? ហេតុអ្វី?

**កិច្ចព្រមព្រៀង:**

ក្នុងករណីយើងសម្រេចចិត្តក្នុងការបញ្ចូលឲ្យមានការផ្លាស់ប្តូរ តើអ្នកអនុញ្ញាតឲ្យយើងប្រើប្រាស់ករណីរបស់អ្នកដែរឬទេ? [ ]មាន [ ] គ្មាន ប្រសិនបើមាន តើអ្នកនឹងអនុញ្ញាតអោយយើងដាក់រូបថតរបស់អ្នកទៅក្នុងរបាយការណ៍របស់ពួកយើងដែរឬទេ? [ ]យល់ព្រម [ ] មិនយល់ព្រម

______________________________

**ហត្ថលេខាអ្នកចូលរួមឆ្លើយ**